# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជារំលឹកមរណសាក្សី
# តាំងគោក ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩
# មុនដំណាំបានដុះឡើងគ្រាប់ត្រូវតែខាប់

**អត្ថបទទី១៖ កិច្ចការ ២០,២៨-៣៨**

សូមបងប្អូនថែរក្សាខ្លួនឯង និងថែរក្សាក្រុមអ្នកជឿទាំងមូលផង ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ទុកផ្ដាក់ឲ្យបងប្អូនធ្វើជាអ្នកទទួលខុសត្រូវនេះ ដើម្បីឲ្យបងប្អូនថែរក្សាព្រះសហគមន៍របស់ព្រះជាម្ចាស់ ដែលព្រះអង្គបានលោះមក ដោយសារព្រះលោហិតរបស់ព្រះអង្គផ្ទាល់។ កក ២០,២៨

**ដំណឹងល្អ៖ យ៉ូហាន ១២,២៣-២៦**

ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា គ្រាប់ស្រូវធ្លាក់ដល់ដី ហើយបើមិនងាប់ទេ គ្រាប់នោះនៅតែមួយដដែល ផ្ទុយទៅវិញ បើគ្រាប់ស្រូវនោះងាប់ វានឹងបង្កើតផលបានច្រើន។ យហ ១២,២៤

បងប្អូនជាទីស្រឡាញ់!

សូមស្វាគមន៍លើទឹកដីនៃមរណសាក្សីប្រទេសកម្ពុជា ប៉ុន្មានថ្ងៃមុនព្រះសហគមន៍នៅប្រទេសថៃបានប្រារព្ធខួប៣៥០ឆ្នាំនៃភូមិភាគស្យាម។ ៣៥០ឆ្នាំដែលស្យាមបានបែកពីកូសាំងស៊ីលកម្ពុជា-ឡាវ ពីដើមយើងមានលោកអភិបាលតែមួយដែលគ្រប់គ្រងព្រះសហគមន៍ទាំងប្រទេសឡាវ ទាំងប្រទេសថៃ ទាំងប្រទេសកម្ពុជា ទាំងប្រទេសវៀតណាម។ ព្រះសហគមន៍របស់យើងនៅប្រទេសកម្ពុជា ទាំងបាត់ដំបង ទាំងកំពង់ចាម ទាំងភ្នំពេញ យើងបានជួបជុំគ្នាដើម្បីនឹករលឹកដល់បងប្អូនដែលបានទទួលមរណភាពក្នុងសម័យខ្មែរក្រហម ដើម្បីនឹករលឹកដល់បងប្អូនគ្រីស្តបរិស័ទ មានលោកអភិបាល ឆ្មារ សាឡាស់ និងសហការី។

បងប្អូនដែលជាគ្រីស្តបរិស័ទ បងប្រុសបងស្រី លោកបូជាចារ្យ លោកអភិបាល ថ្ងៃនេះនៅក្បែរឈើឆ្កាងតាំងគោក នៅក្បែរគ្រែដែលមរណសាក្សីយើងបានថ្វាយសក្ការៈបូជាដ៏ពិសេសបំផុត ដោយសុខចិត្តបូជាជីវិត។ យើងបានស្ដាប់លោកប៉ូលនិយាយថា "**បងប្អូនជាទីស្រឡាញ់ជាពេលវេលាដើម្បីទទួលខុសត្រូវលើព្រះសហគមន៍របស់ព្រះជាម្ចាស់ផ្ទាល់ខ្លួន**" ពិតមែនថ្ងៃនេះព្រះសហគមន៍នៅប្រទេសកម្ពុជាដែលយើងទទួលខុសត្រូវ នៅក្បែរព្រះជាម្ចាស់ នៅក្បែរបងប្អូនដែលបានទទួលមរណភាពនៅក្នុងសម័យខ្មែរក្រហម នៅក្បែរបុព្វបុរសរបស់យើងនៅក្នុងជំនឿ នៅក្បែរបុព្វបុរសរបស់យើងដែលបានសាងសង់អង្គរវត្ត រួមជាមួយគ្នាយើងត្រូវភ្ជាក់ស្មារតី

ដើម្បីទទួលខុសត្រូវនៅលើព្រះសហគមន៍កម្ពុជា ដែលយើងបានទទួលជាមរតកនៅពេលនេះ ដើម្បីរៀបចំអនាគត។ ដើម្បីទទួលខុសត្រូវគឺ៖

**ទីមួយ** យើងទទួលខុសត្រូវព្រះសហគមន៍ដែលជាផ្ទះរបស់យើង នៅក្នុងផ្ទះហ្នឹងយើងមានមហាគ្រួសារមួយយ៉ាងធំណាស់ យើងរៀងៗខ្លួនយើងទទួលខុសត្រូវនៅក្នុងតួនាទីដែលព្រះជាម្ចាស់បានប្រគល់ឲ្យ។ នៅក្នុងព្រះគម្ពីរដំណឹងល្អព្រះយេស៊ូមានព្រះបន្ទូលថា "**បើអ្នកណាចង់បម្រើខ្ញុំ អ្នកនោះត្រូវមកតាមខ្ញុំ ខ្ញុំនៅទីណាអ្នកបម្រើខ្ញុំក៏នៅទីនោះដែរ**" នេះជាតួនាទីរបស់យើងទាំងអស់គ្នាជាគ្រីស្តបរិស័ទ។ យើងជាអ្នកបម្រើនៅក្នុងព្រះសហគមន៍ ដែលជាផ្ទះរបស់យើងផ្ទាល់ យើងមានមហាគ្រួសារដែលចេញចូលជារៀងរាល់ថ្ងៃ ឲ្យយើងធ្វើជាម្ចាស់ផ្ទះយ៉ាងច្បាស់លាស់ ដែលចេះស្វាគមន៍ ដែលចេះបម្រើដោយញញឹម ដែលចេះស្រឡាញ់និងចេះផ្តល់សេចក្តីសង្ឃឹម។ នេះជាពេលវេលាមួយ ដើម្បីសម្លឹងមើលឈើឆ្កាងនៅក្បែរយើង ដែលបានដាំនៅក្នុងស្រែដ៏តូចមួយយើងបានសាបព្រោះពូជដែលកំពុងដុះឡើងបន្តិចម្តងៗ។ យើងបានស្តាប់យើងថា "**មុនដំណាំបានដុះឡើងគ្រាប់ត្រូវតែងាប់ ប្រសិនបើគ្រាប់មិនងាប់ឥតមានផ្លែយ៉ាងច្រើន**" ។ ដូច្នេះ សម្រាប់យើងត្រូវនឹកឃើញដល់ការទទួលខុសត្រូវរបស់យើង ជាពេលវេលាដើម្បីឲ្យទំលាប់អាក្រក់របស់យើងងាប់ បណ្តេញអ្វីៗដែលណែនាំឲ្យយើងនៅឆ្ងាយពីព្រះជាម្ចាស់។ ជាពិសេស នឹកដល់ទស្សនៈដែលយើងមានសម្រាប់ពិភពលោក សម្រាប់ព្រះសហគមន៍របស់យើងផ្ទាល់ ដើម្បីបញ្ចូលនៅក្នុងទឹកដីនៃមរណសាក្សីនៅទីនេះ និងដើម្បីកើតសាជាថ្មី ដោយយើងមានភ្នែកថ្មី ដួងចិត្តថ្មី។ ឲ្យយើងកើតសាជាថ្មីលើទឹកដីតាំងគោក ដែលជាកន្លែងមួយដែលយើងអាចកើតពិតមែន។

**ទីពីរ** យុវជនយុវនារី ដែលមានសេចក្តីសង្ឃឹមអំណរសប្បាយនៅក្នុងខ្លួន ដែលពោរពេញដោយសុបិនសម្រាប់អនាគត ពេលយើងមកដល់តាំងគោកដែលជាទឹកដីរបស់បុព្វបុរសយើងជាពេលវេលាដើម្បីកើតសាជាថ្មីម្តងទៀត។ ពេលយើងទៅវិញឲ្យយើងមានកម្លាំងថ្មី សេចក្តីស្រឡាញ់ថែមទៀត ដើម្បីមានគម្រោងការថ្មីៗជម្រុញលោកបូជាចារ្យ លោកអភិបាល ឲ្យភ្ញាក់ស្មារតីដើម្បីធ្វើជាគ្រូគង្វាលដ៏សប្បុរស និងណែនាំឲ្យយុវជនយុវនារីអាចបំពេញគ្រោងការរបស់គេ បំពេញសុបិនរបស់គេនៅបច្ចុប្បន្ននេះ។ ជាពេលវេលាដើម្បីកើតសាជាថ្មី ដើម្បីយកចិត្តទុកដាក់ទទួលខុសត្រូវនៅក្នុងផ្ទះរបស់យើងដែលជាព្រះសហគមន៍កម្ពុជាជាមហាគ្រួសាររបស់យើង។ លើសពីនេះទៅទៀត យើងត្រូវតែទទួលខុសត្រូវនៅក្នុងការប្រកាសដំណឹងល្អ យើងឃើញលោកប៉ូល លោកបារណាបាស់ យើងឃើញរបៀបដែលក្រុមគ្រីស្តទូតយកចិត្តទុកដាក់ដើម្បីប្រកាសដំណឹងល្អ យើងឃើញរបៀបដែលក្រុមគ្រីស្តទូតទៅជាមិត្តសម្លាញ់យ៉ាងជិតស្និទ្ធ

របស់ព្រះយេស៊ូ ជាសាវ័ករបស់ព្រះគ្រីស្ត ជាទូតរបស់ព្រះគ្រីស្តដើម្បីប្រកាសដំណឹងល្អដល់ពិភពលោកទាំងមូល នេះជាបេសកកម្មរបស់យើង។ យើងមកដល់ទឹកដីមរណសាក្សីយើង ជាពេលវេលាដើម្បីស្តាប់សម្លេងខ្សឹបៗរបស់លោកអភិបាល ឆ្មារ សាឡ្យាស់ លោកឆ្មារ សាឡ្យឹម លោកសម្រើន ដែលបានថ្វាយអភិបូជាលើគ្រែនៅទីនេះ ថ្វាយអភិបូជានៅក្នុងភាពស្ងៀមស្ងាត់ ដើម្បីការពារភ្នែកម្ចាស់មើលឃើញគេ។ ជាពេលវេលាដើម្បីនៅស្ងៀមស្ងាត់ ដើម្បីស្តាប់សម្លេងខ្សឹបៗរបស់មរណសាក្សីដែលកំពុងអធិដ្ឋាន ជាពេលវេលាដើម្បីលួចមើលលោកអភិបាល ឆ្មារ សាឡ្យាស់ នៅពេលខែភ្លឺគាត់បានយកកូនសៀវភៅដែលគាត់លាក់ទុកជាទ្រព្យសម្បត្តិពិសេស ដែលអង្គការហាមជាដាច់ខាតនៅសម័យនោះ។ នោះជាព្រះគម្ពីរ នៅពេលទាំងអស់គ្នាកំពុងដេកលក់ គាត់បានយកសៀវភៅនោះមកអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីចិញ្ចឹមជីវិតរបស់គាត់។ ឲ្យយើងលួចមើលលោកអភិបាល ឆ្មារ សាឡ្យាស់ ដែលបានអធិដ្ឋានសម្រាប់ប្រជារាស្ត្ររបស់លោក ឲ្យយើងស្តាប់បងស្រីលីលី ដែលកំពុងច្រៀងបំពេរកូនក្មេង បទចម្រៀងដែលគាត់នឹកឃើញដើម្បីមើលថែកូនក្មេង ដោយសារឪពុកម្តាយរបស់គេបានទៅធ្វើការឲ្យអង្គការទាំងអស់កម្លាំង ទាំងឈឺ មានច្រើនដែលឪពុកម្តាយមិនបានត្រលប់មកវិញទេព្រោះគាត់ស្លាប់ហើយ។

**ទីបី** យើងត្រូវការចាក់ឫសយ៉ាងជ្រៅនៅលើទឹកដីមរណសាក្សីយើង យើងជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ដែលត្រូវតែចាក់ឫសលើទឹកដីមរណសាក្សី ដើម្បីហើរទៅឆ្ងាយប្រកាសដំណឹងល្អ ថ្ងៃនេះព្រះជាម្ចាស់មានព្រះជន្មគង់នៅ។ សូមហើរ ដើម្បីមើលសង្គមរបស់យើងដែលកំពុងស្រេកឃ្លានអំពីជីវិតនៅក្នុងដួងចិត្ត មនុស្សលោកមិនមែនមានតែរូបកាយដែលត្រូវចិញ្ចឹមឲ្យឆ្អែត មនុស្សលោកមានវិញ្ញាណដែលត្រូវការមានព្រះជាម្ចាស់ ដែលណែនាំឲ្យយើងបើកចិត្តគំនិតទូលំទូលាយ ដើម្បីស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើង។ នៅក្នុងសង្គមរបស់យើងសព្វថ្ងៃ ទោះបីរីកចម្រើនក៏ដោយមានប៉ុន្មានកន្លែងដែលសេចក្តីស្រឡាញ់មិនបានទៅដល់ មានប៉ុន្មានកន្លែងដែលគេបំផ្លាញសេចក្តីស្រឡាញ់ ត្រូវគេឆ្កាងសាជាថ្មី។ ដូច្នេះ ឲ្យយើងឈរឡើងដើម្បីស្រែក សូមស្រឡាញ់គ្នាទៅវិញទៅមក ដោយយើងធ្វើជាគំរូនៅក្នុងសេចក្តីស្រឡាញ់នេះ។ ពិតមែនព្រះយេស៊ូមានព្រះជន្មគង់នៅ ព្រះយេស៊ូប្រទានជីវិតឲ្យយើងយកចិត្តទុកដាក់ទទួលខុសត្រូវនៅក្នុងការប្រកាសដំណឹងល្អ។

**ទីបួន** ឲ្យយើងយកចិត្តទុកដាក់និងទទួលខុសត្រូវនៅចំពោះមុខសង្គមរបស់យើង សន្តប៉ូលបាននិយាយថា "**ខ្ញុំមិនដែលទីពឹងលើបងប្អូនទេ ខ្ញុំមិនដែលធ្វើជាអ្នកសុំទាន ខ្ញុំបានយកចិត្តទុកដាក់ចិញ្ចឹមជីវិតរបស់ខ្ញុំខ្លួនឯង និងបានយកចិត្តទុកដាក់ជួយបងប្អូនឯទៀតៗដែលកំពុងខ្វះ**

**ខាត**”។ ពិតមែន កុំឲ្យយើងធ្វើជាអ្នកសុំទាន ឲ្យយើងពោរពេញដោយកិត្តិយសនិងមោទនភាព នៅក្នុងការងារដែលយើងធ្វើជាប្រចាំ នៅក្នុងសមត្ថភាពដែលយើងមានដើម្បីចិញ្ចឹមគ្រួសាររបស់យើង ដោយយកចិត្តទុកដាក់បើកចិត្តគំនិតរបស់យើងយ៉ាងធំទូលំទូលាយដើម្បីជួយបងប្អូនឯទៀតៗដែលខ្វះខាត ដែលជាអ្នកតូចតាច ដែលគ្មានសេចក្ដីសង្ឃឹម។ ជួនកាលដៃរបស់យើងអាចបើកធំណាស់ នៅក្នុងភាពលោភលន់ ដូច្នេះនេះជាពេលវេលាឲ្យយើងបើកដៃដើម្បីឲ្យ ឲ្យយើងបើកដួងចិត្តដើម្បីស្រឡាញ់។ ឲ្យយើងទូលំទូលាយនៅក្នុងការថ្វាយដង្វាយ ឲ្យយើងទូលំទូលាយនៅក្នុងសកម្មភាពសង្គហៈធម៌មេត្តាករុណា ឲ្យយើងចេះរត់ទៅប្រាប់ព្រះសហគមន៍ថាយើងបានឃើញអ្នកក្រីក្រ អ្នកជំងឺ កូនក្មេង ដែលកំពុងពិបាកនិងជួយគេ។ ឲ្យយើងពោរពេញដោយភាពឆ្នៃប្រឌិត ដើម្បីរៀបចំឲ្យបងប្អូនតូចតាចមានការងារធ្វើ ឲ្យរៀបចំការអប់រំសម្រាប់បងប្អូនដែលគ្មានការអប់រំដូចគេ ដោយសារសង្គមបានភ្លេចគេ។ សូមឲ្យគ្រួសារនីមួយៗ ទៅជាគ្រួសារដែលចេះស្វាគមន៍នៅក្នុងផ្ទះដែលគ្មានរបង នៅក្នុងផ្ទះដែលបានបើកទ្វារ ឲ្យយើងដកចេញពូជនៃចិត្តលោភលន់ ពូជនៃចិត្តអាត្មានិយម ពូជនៃភាពពុករលួយនៅក្នុងសង្គម នៅក្នុងជីវិតរបស់យើង ដើម្បីមានតែសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់អាចដុះឡើងនៅក្នុងជីវិតរបស់យើងផង នៅក្នុងព្រះសហគមន៍យើងផង នៅក្នុងសង្គមយើងផង។

សូមបងប្អូនសម្លឹងមើលមរណសាក្សីរបស់យើង គេបានចេញពីទីក្រុងភ្នំពេញ ពីកន្លែងនានានៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រួមជាមួយប្រជារាស្ត្រកម្ពុជានៅតាមផ្លូវទាំងក្ដៅទាំងភ្លៀងដោយឥតមានអ្វីសោះមានតែជំនឿលើព្រះជាម្ចាស់ ដោយសារជំនឿបានសង្គ្រោះយើងយ៉ាងពិតប្រាកដមែន។ នៅមុខព្រះជាម្ចាស់ នៅមុខបុព្វបុរសរបស់យើងនៅក្នុងជំនឿ នៅមុខឈើឆ្កាងនៃមរណសាក្សី សូមឈរឡើងនឹងប្រកាសថា “**បងប្អូនជាទីស្រឡាញ់ តើបងប្អូនសុខចិត្តទទួលខុសត្រូវយ៉ាងខ្ពស់បំផុតនៅក្នុងព្រះសហគមន៍ផ្ទាល់ខ្លួន អស់ពីដួងចិត្ត អស់ពីជំនឿ អស់ពីសេចក្ដីស្រឡាញ់ឬទេ? បងប្អូនជាទីស្រឡាញ់ តើបងប្អូនសុខចិត្តប្រកាសដំណឹងល្អអំពីព្រះយេស៊ូដែលមានព្រះជន្មគង់នៅសព្វថ្ងៃ ដោយលះបង់ចោលមាសាតាំងនិងដោយមិនចាញ់អ្វីៗទាំងអស់ដែលរារាំង ដើម្បីប្រកាសដំណឹងល្អឬទេ? បងប្អូនជាទីស្រឡាញ់ តើបងប្អូនសុខចិត្តបើកចិត្តគំនិតយ៉ាងពិតប្រាកដនៅក្នុងសេចក្ដីពិត ដើម្បីស្រឡាញ់ អាណិត មេត្តា អ្នកតូចតាចនៅក្នុងសង្គមរបស់យើងឬទេ?**” សូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូនទាំងអស់ សូមព្រះជាម្ចាស់ស្វាគមន៍យើង ស្វាគមន៍វិញ្ញាណក្ខន្ធរបស់បងប្អូនយើងនៅក្នុងសេចក្ដីសុខសាន្តរបស់ព្រះអង្គ សូមមរណសាក្សីនៃប្រទេសកម្ពុជាអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ សម្រាប់យើងដែលជាមនុស្សទន់ខ្សោយ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ អាលេលូយា អាលេលូយា៕